ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

# កម្មវិធីសិក្សាលម្អិត

មុខវិជ្ជា

# ភូមិវិទ្យា

សម្រាប់

## កម្រិតមធ្យមសិក្សាទុតិយភូមិ

២០១៨

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**
**លេខ:** ៥០៤ **អយក.**ប្រក

# ប្រកាស
## ស្តីពី
## ការដាក់ឱ្យប្រើប្រាស់កម្មវិធីសិក្សាលម្អិតគ្រប់មុខវិជ្ជា កម្រិតមធ្យមសិក្សាទុតិយភូមិ

## រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣២ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអប់រំ
- បានឃើញអនុក្រឹត្យលេខ១៥៦ អនក្រ.បក ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញប្រកាសលេខ៣០២ អយក.ប្រក ចុះថ្ងៃទី៩ ខែមីនា ឆ្នាំ២០១៧ ស្តីពីការដាក់ឱ្យអនុវត្តក្របខណ្ឌកម្មវិធីសិក្សាចំណេះទូទៅនិងអប់រំបច្ចេកទេស
- តាមសំណើរបស់គណៈកម្មការនិងអនុគណៈកម្មការកែលម្អកម្មវិធីសិក្សានិងសៀវភៅសិក្សាគោល

## សម្រេច

**ប្រការ១ ..**

ប្រកាសដាក់ឱ្យប្រើជាផ្លូវការ "**កម្មវិធីសិក្សាលម្អិតគ្រប់មុខវិជ្ជាកម្រិតមធ្យមសិក្សាទុតិយភូមិ**" ។



អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ: www.moeys.gov.kh

**ប្រការ២** .-

កម្មវិធីសិក្សាលម្អិតគ្រប់មុខវិជ្ជាកម្រិតមធ្យមសិក្សាទុតិយភូមិនេះ មានមាតិកាសំខាន់ៗ ដូចខាងក្រោម៖

- សេចក្តីផ្តើម
- គោលបំណង
- គោលគំនិតសំខាន់ៗ
- របាយម៉ោងសិក្សា
- ការណែនាំអនុវត្ត
- ការវាយតម្លៃ
- តារាងកម្មវិធីសិក្សា

ខ្លឹមសារលម្អិតនៃកម្មវិធីសិក្សាលម្អិតគ្រប់មុខវិជ្ជាកម្រិតមធ្យមសិក្សាទុតិយភូមិជាឧបសម្ព័ន្ធនៃប្រកាសនេះ។

**ប្រការ៣** .-

បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះត្រូវទុកជានិរាករណ៍។

**ប្រការ៤** .-

អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋានអប់រំ អគ្គនាយកនៃអគ្គនាយដ្ឋានឧត្តមសិក្សា អគ្គនាយកនៃអគ្គនាយកដ្ឋានគោលនយោបាយនិងផែនការ អគ្គនាយកនៃអគ្គនាយកដ្ឋានយុវជន អគ្គនាយកនៃអគ្គនាយកដ្ឋានកីឡា អគ្គាធិការនៃអគ្គាធិការដ្ឋាន ប្រធាននាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា ប្រធាននាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ ប្រធាននាយកដ្ឋានបណ្តុះបណ្តាលនិងវិក្រឹតការ និងអ្នកពាក់ព័ន្ធត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះឱ្យមានប្រសិទ្ធភាពតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃសុក្រ ១១រោច ខែភទ្របទ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី០៥ ខែតុលា ឆ្នាំ២០១៨

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិតសភាចារ្យ ហង់ ជួន ណារ៉ុន**

**កន្លែងទទួល** :

- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យរដ្ឋមន្ត្រីក្រសួង អយក
  "ដើម្បីជូនជ្រាបជាព័ត៌មាន"
- អង្គភាពក្រោមឱវាទក្រសួងអប់រំ យុវជន និងកីឡា
- មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត
- ដូចប្រការ៤ "ដើម្បីអនុវត្ត"
- ឯកសារ កាលប្បវត្តិ អគ.អរ

# បុព្វកថា

ការអប់រំជាវិស័យគន្លឹះមួយក្នុងការរួមចំណែកអភិវឌ្ឍធនធានមនុស្ស សំដៅជំរុញឱ្យសង្គមនិងសេដ្ឋកិច្ចរីកចម្រើន។ បច្ចុប្បន្ននេះ សង្គមនិងសេដ្ឋកិច្ចមានការអភិវឌ្ឍនិងការរីកចម្រើនដែលជាកម្លាំងចលករជំរុញឱ្យមានការកែលម្អការអប់រំ ដើម្បីអាចឆ្លើយតបទៅនឹងការវិវត្តថ្មីៗរបស់សង្គមនិងសេដ្ឋកិច្ច។ ប៉ុន្មានទសវត្សរ៍ចុងក្រោយនៃសតវត្សរ៍ទី២០និងដើមសតវត្សរ៍ទី២១នេះ សង្គមនិងសេដ្ឋកិច្ចឈានដល់បរិបទថ្មីដែលមិនធ្លាប់មានកន្លងមកដោយពិភពលោកកាន់តែបើកចំហ ការប្រកួតប្រជែងកាន់តែស្រួចស្រាល់ជាងមុន វិស័យបច្ចេកវិទ្យា និងវិទ្យាសាស្ត្រកាន់តែទំនើបនិងប្រសើរឡើង។ កត្តាទាំងនេះនាំឱ្យប្រទេសឬជាតិសាសន៍នានាខិតខំពង្រឹងធនធានមនុស្សរបស់ខ្លួន ដើម្បីតាមឱ្យទាន់និងអាចឈរជើងប្រកបដោយឧត្តមភាពក្នុងបរិបទថ្មីនៃសង្គមនិងសេដ្ឋកិច្ចរបស់ពិភពលោក។

ដើម្បីឆ្លើយតបនឹងតម្រូវការរីកចម្រើនរបស់សង្គមនិងសេដ្ឋកិច្ចថ្មី ក្រសួងអប់រំ យុវជន និងកីឡា បានដាក់ចេញនូវការកែទម្រង់កម្មវិធីសិក្សាអប់រំចំណេះទូទៅដែលជាមូលដ្ឋានសម្រាប់ឱ្យអ្នកសិក្សាអាចបន្តការសិក្សា និងទទួលការបណ្តុះបណ្តាលផ្សេងៗទៀត សំដៅលើកកម្ពស់គុណភាពធនធានមនុស្សប្រកបដោយវិជ្ជាសម្បទា បំណិនសម្បទា ចរិយាសម្បទា និងកាយសម្បទា ដែលជាធាតុសំខាន់ក្នុងកម្មវិធីសិក្សា។ កម្មវិធីសិក្សាលម្អិតនេះចែកជាបីភូមិសិក្សាដាច់ដោយឡែកពីគ្នាតែប្រទាក់ក្រឡានិងគាំទ្រគ្នា។ កម្មវិធីសិក្សាលម្អិតកម្រិតមធ្យមសិក្សាទុតិយភូមិនេះ បានបន្ថែមម៉ោងសិក្សាច្រើនជាងមុនទៅក្នុងកម្មវិធីសិក្សា។ ការកែទម្រង់កម្មវិធីសិក្សានៅកម្រិតមធ្យមសិក្សាទុតិយភូមិ សំដៅកសាងមូលដ្ឋានគ្រឹះសម្រាប់ការអប់រំនៅកម្រិតបន្តដោយពង្រីកវិសាលភាពចំណេះដឹង បំណិនការអប់រំសីលធម៌ គំនិតច្នៃប្រឌិត គំនិតបង្កើតថ្មី និងស្មារតីសហគ្រិនភាព ព្រមទាំងផ្តល់នូវចំណេះដឹងមូលដ្ឋានផ្នែកបច្ចេកវិទ្យា បំណិនសតវត្សរ៍ទី២១ និងបំណិនសិក្សាពេញមួយជីវិត ដើម្បីឱ្យក្លាយខ្លួនជាបុគ្គលល្អដែលមានប្រយោជន៍សម្រាប់ខ្លួនឯង គ្រួសារ សហគមន៍ ប្រទេសជាតិ និងពិភពលោក។

ក្រសួង សង្ឃឹមយ៉ាងមុតមាំថា កម្មវិធីសិក្សាលម្អិតនេះនឹងបម្រើជាប្រយោជន៍ដ៏មានប្រសិទ្ធភាពក្នុងការអភិវឌ្ឍសៀវភៅសិក្សាគោល សម្ភារៈឧបទេស ឯកសារជំនួយនានាក្នុងការរៀននិងបង្រៀន និងឧបករណ៍ពិនិត្យតាមដាន វាយតម្លៃផ្សេងៗ។

ក្រសួង សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះអនុគណៈកម្មការមុខវិជ្ជាឯកទេសទាំងអស់ លេខាធិការដ្ឋានកែលម្អកម្មវិធីសិក្សានិងសៀវភៅសិក្សាគោល នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា និងអ្នកពាក់ព័ន្ធទាំងអស់ដែលបានចូលរួមនិងដើរតួនាទីស្នូលក្នុងការសម្របសម្រួល ព្រមទាំងដឹកនាំរៀបចំតាក់តែងកម្មវិធីសិក្សាលម្អិតនេះឱ្យបានសម្រេចជាផ្លែផ្កាឡើងនាពេលនេះ។

ថ្ងៃ អង្គារ ៧រោច ខែ ជេស្ឋ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ មិថុនា ឆ្នាំ២០១៨

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

បណ្ឌិតសភាចារ្យ **ហង់ ជួន ណារ៉ុន**

# អារម្ភកថា

ការកែទម្រង់វិស័យអប់រំជានិន្នាការមួយស្របទៅនឹងការវិវត្តយ៉ាងលឿនក្នុងសម័យបច្ចុប្បន្ននិងស្របពេលដែលពិភពលោកមានការប្រែប្រួលយ៉ាងឆាប់រហ័ស។ ប្រទេសជាច្រើននៅលើពិភពលោកបានទទួលស្គាល់ថា បាតុភូតសង្គមបានផ្តោតទៅលើគម្រោងនៃកម្មវិធីសិក្សាដែលមានលក្ខណៈទន់ភ្លន់។ ទស្សនវិជ្ជាថ្មីនៃការបង្រៀនមានទំនោរកំណត់បញ្ចូលលទ្ធផលសិក្សា ជាគោលបំណងចម្បងក្នុងការអភិវឌ្ឍកម្មវិធីសិក្សា។ បញ្ញត្តិនៃកម្មវិធីសិក្សាបច្ចុប្បន្នបានធ្វើឱ្យមានការផ្លាស់ប្តូរទស្សនៈ គោលគំនិតគរុកោសល្យ និងវិធីសាស្ត្រសម័យមុន ដោយប្រែក្លាយពីការបង្រៀនមកជាការរៀនដោយយកសកម្មភាពសិស្សជាគោល (គោលវិធីសិស្សមជ្ឈមណ្ឌល) ពីការផ្ទេរចំណេះដឹង មកជាការស្ថាបនាពុទ្ធិដោយខ្លួនឯង ឬសិស្សអាចសម្រេចលទ្ធផលសិក្សាតាមវិធីសាស្ត្រចម្រុះ និងអភិវឌ្ឍវិជ្ជាសម្បទា បំណិនសម្បទា និងចរិយាសម្បទា ដើម្បីឱ្យសិស្សស្រឡាញ់ការសិក្សាពេញមួយជីវិត ព្រមទាំងធានាគុណភាពអប់រំប្រកបដោយចីរភាព។

ការអភិវឌ្ឍកម្មវិធីសិក្សា ត្រូវបានយកចិត្តទុកដាក់ និងមានការវិវត្តយ៉ាងលឿនក្នុងសម័យបច្ចុប្បន្នដោយសារពិភពលោកមានការប្រែប្រួលយ៉ាងឆាប់រហ័ស។ បញ្ញត្តិនៃកម្មវិធីសិក្សា បានធ្វើឱ្យមានការផ្លាស់ប្តូរទស្សនៈ គោលគំនិតគរុកោសល្យ និងវិធីសាស្ត្រសម័យមុន ដោយប្រែក្លាយពីការបង្រៀន មកជាការរៀនដោយសកម្ម ប្រកបដោយភាពច្នៃប្រឌិត និងការបង្កើតថ្មីដើម្បីឱ្យសិស្សស្រឡាញ់ការសិក្សាពេញមួយជីវិត។

ការវិវត្តនៃការកែលម្អកម្មវិធីសិក្សា ឆ្ពោះទៅរកគុណភាពអប់រំ និងធ្វើឱ្យជីវិតរស់នៅកាន់តែល្អប្រសើរ ដោយបង្កើនការផ្សារភ្ជាប់កម្មវិធីសិក្សាទៅនឹងជីវភាពរស់នៅប្រចាំថ្ងៃ។ ទំនោរនៃការអប់រំនៅប្រទេសកម្ពុជា មិនខុសពីទំនោរនៃការអប់រំលើពិភពលោកទេ ព្រោះតម្រូវការអភិវឌ្ឍសង្គមជាតិ ការរីកចម្រើនផ្នែកសេដ្ឋកិច្ចមិនអាចខ្វះធនធានមនុស្សបានឡើយ។

អាស្រ័យហេតុនេះ ក្រសួងអប់រំ យុវជន និងកីឡា បានកែលម្អកម្មវិធីសិក្សាគ្រប់មុខវិជ្ជាទាំងមុខវិជ្ជាវិទ្យាសាស្ត្រទាំងមុខវិជ្ជាសិក្សាសង្គម ក្នុងនោះមុខវិជ្ជាភូមិវិទ្យា ក៏ជាតម្រូវការនៃផលប្រយោជន៍របស់អ្នកសិក្សា អ្នកវិទ្យាសាស្ត្រ និងវិនិយោគិនទាំងអស់ផងដែរ ។

កម្មវិធីសិក្សាលម្អិតមុខវិជ្ជាភូមិវិទ្យា សម្រាប់កម្រិតមធ្យមសិក្សាទុតិយភូមិនេះ ត្រូវបានរៀបចំឡើងឱ្យស្របទៅនឹងគោលនយោបាយជាតិក្របខណ្ឌកម្មវិធីសិក្សាអប់រំចំណេះទូទៅនិងអប់រំបច្ចេកទេស ស្របទៅនឹងស្ថានភាពអប់រំនៃបណ្តាប្រទេសក្នុងសហគមន៍អាស៊ាន និងពិភពលោក ដែលធានាឱ្យអ្នកសិក្សាមានសមត្ថភាព និងបន្តការសិក្សាទៅសាលាបច្ចេកទេស ព្រមទាំងមហាវិទ្យាល័យនានា។

កម្មវិធីសិក្សាលម្អិតនេះ មានរៀបរាប់ពីគោលបំណងនៃកម្មវិធីសិក្សា ខ្លឹមសារសំខាន់ៗ របាយម៉ោងសិក្សានៅកម្រិតមធ្យមសិក្សាទុតិយភូមិ វិធីសាស្ត្របង្រៀន ការវាយតម្លៃ និងកម្មវិធីសិក្សាលម្អិតតាមកម្រិតថ្នាក់។

អនុគណៈកម្មការមុខវិជ្ជាឯកទេសភូមិវិទ្យាសម្រាប់កម្រិតមធ្យមសិក្សាទុតិយភូមិនេះសូមថ្លែងអំណរគុណដល់ក្រសួងអប់រំ យុវជន និងកីឡាដែលបានគាំទ្ររៀបចំកម្មវិធីសិក្សាលម្អិតនេះឡើង។

**អនុគណៈកម្មការមុខវិជ្ជាឯកទេសភូមិវិទ្យា**

# មាតិកា


ប្រកាស........................................................................................................ i
បុព្វកថា........................................................................................................ iii
អារម្ភកថា........................................................................................................ iv
មាតិកា........................................................................................................ v
១- សេចក្តីផ្តើម........................................................................................................ 1
២- គោលបំណង........................................................................................................ 2
៣- គោលគំនិតៗសំខាន់ៗ........................................................................................................ 3
៤- របាយម៉ោងសិក្សា........................................................................................................ 3
៥- ការណែនាំអនុវត្ត........................................................................................................ 4
៦- ការវាយតម្លៃ........................................................................................................ 4
៧- តារាងកម្មវិធីសិក្សា........................................................................................................ 5
៧.១- កម្មវិធីសិក្សាលម្អិតថ្នាក់ទី១០........................................................................................................ 5
៧.២- កម្មវិធីសិក្សាលម្អិតថ្នាក់ទី១១........................................................................................................ 14
៧.៣- កម្មវិធីសិក្សាលម្អិតថ្នាក់ទី១២........................................................................................................ 24
៨- ឯកសារយោង........................................................................................................ 34
៩- បញ្ជីឈ្មោះគណៈកម្មការ........................................................................................................ 35

## ១- សេចក្ដីផ្ដើម

ការរីកចម្រើនខាងវិទ្យាសាស្ត្រ បច្ចេកវិទ្យានៅសហសវត្សថ្មី និងកំណើនប្រជាជននៅលើពិភពលោកនាំឱ្យមានសន្ទុះកើនឡើងនៃតម្រូវការ និងការផ្គត់ផ្គង់របស់មនុស្ស។ ក៏ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយក៏នៅតែមានមនុស្សជាច្រើននៅលើពិភពលោកកំពុងតែមានទុក្ខកង្វល់នឹងកង្វះលទ្ធភាពបំពេញសេចក្ដីត្រូវការផ្សេងៗក្នុងជីវភាពរស់នៅរបស់ខ្លួន។

ពិតណាស់សន្ទុះរីកចម្រើននៃវិទ្យាសាស្ត្រនិងបច្ចេកវិទ្យាអាចនាំឱ្យមនុស្សធ្វើអ្វីៗបានទាំងអស់រាប់ទាំងអំពើអវិជ្ជមានផងដោយមិនមានអំណះអំណាងត្រឹមត្រូវ ឬផ្អែកទៅតាមគោលការណ៍ច្បាប់ណាមួយ។ ដោយយល់ឃើញដូច្នេះការអប់រំផ្នែកសិក្សាសង្គមមធ្យមសិក្សាទុតិយភូមិនៅកម្ពុជា បានចូលរួមចំណែកធ្វើឱ្យសិស្សមានការលូតលាស់គ្រប់ផ្នែក និងមានតុល្យភាពរវាងរូបកាយ បញ្ញា ស្មារតី និងសញ្ចេតនា ដើម្បីក្លាយជាពលរដ្ឋដ៏ថ្លៃថ្នូររបស់សង្គមជាតិនិងពិភពលោក។

ជាក់ស្ដែងការវិវត្តនៃការកែលម្អកម្មវិធីសិក្សា ឆ្ពោះទៅរកគុណភាពអប់រំ និងធ្វើឱ្យជីវិតរស់នៅកាន់តែល្អប្រសើរដោយបង្កើនការផ្សារភ្ជាប់កម្មវិធីសិក្សាទៅនឹងជីវភាពរស់នៅប្រចាំថ្ងៃ។ ទំនោរនៃការអប់រំនៅប្រទេសកម្ពុជា ស្របទៅនឹងទំនោរនៃការអប់រំលើពិភពលោកបច្ចុប្បន្ន ព្រោះការអភិវឌ្ឍសង្គមជាតិនិងការរីកចម្រើនផ្នែកសេដ្ឋកិច្ច ចាំបាច់ត្រូវការធនធានមនុស្សដែលប្រកបដោយសីលធម៌និងគុណធម៌។

ដូច្នេះការអភិវឌ្ឍកម្មវិធីសិក្សា ត្រូវបានយកចិត្តទុកដាក់ និងមានការវិវត្តយ៉ាងលឿនក្នុងសម័យបច្ចុប្បន្នការប្រែប្រួលយ៉ាងឆាប់រហ័សនៃសេដ្ឋកិច្ចកម្ពុជា។ នៅក្នុងដំណាក់កាលនៃការអភិវឌ្ឍកម្មវិធីសិក្សានេះ ដើម្បីធ្វើឱ្យសមត្ថភាពសិស្សដែលបញ្ចប់ការសិក្សាពីភូមិសិក្សានីមួយៗ ដោយទទួលបាននូវវិជ្ជាសម្បទា បំណិនសម្បទា និងចរិយាសម្បទា សម្រាប់ជីវិតរស់នៅប្រចាំថ្ងៃ និងសម្រាប់បន្តការសិក្សាទៅមុខទៀត។

ដើម្បីឆ្លើយតបទៅនឹងតម្រូវការនេះមុខវិជ្ជាភូមិវិទ្យាត្រូវបានរៀបចំឡើងក្នុងគោលបំណងបណ្ដុះបណ្ដាលមូលដ្ឋានគ្រឹះនៃលក្ខណសម្បត្តិ និងសមត្ថភាពមានភាពម្ចាស់ការនៅក្នុងសង្គមសកលភាវូបនីយកម្ម។ សកម្មភាពស្រាវជ្រាវរកបញ្ហា របៀបគិត និងវិធីក្នុងការដោះស្រាយ ដូចជាផ្ដោតការយកចិត្តទុកដាក់លើលក្ខណៈពិសេសនៃអន្តរទំនាក់ទំនងទីតាំងនិងទីកន្លែងរវាងមនុស្សនិងបរិស្ថានធម្មជាតិសកម្មភាពការងារទាក់ទងទៅនឹងលំហភូមិសាស្ត្រតំបន់។ បណ្ដុះសមត្ថភាពធ្វើការងារជាក្រុម ការជ្រើសរើសវិធីយកមកដោះស្រាយ គំនិតច្នៃប្រឌិតសម្រាប់ជីវភាពរស់នៅប្រចាំថ្ងៃ។

ជារួមមុខវិជ្ជាភូមិវិទ្យា បានផ្ដល់នូវចំណេះដឹង និងវិធីស្វែងយល់ពីបទពិសោធក្នុងការដោះស្រាយបញ្ហានានាដែលពាក់ព័ន្ធនឹងលក្ខខណ្ឌជីវភាពរស់នៅក្នុងប្រទេស និងតំបន់ផ្សេងៗនៅលើពិភពលោក។ អ្នកសិក្សាមុខវិជ្ជាភូមិវិទ្យានឹងមានសមត្ថភាពមូលដ្ឋាន ដើម្បីសិក្សាបន្ត និងមានចំណេះដឹងដែលពាក់ព័ន្ធនឹងការដឹកនាំគ្រប់គ្រងសេដ្ឋកិច្ចការវាយតម្លៃប្រភេទដីតាមទីតាំងនីមួយៗសម្រាប់ការងារកសិកម្ម ការជ្រើសរើសទីតាំងដែលជាប្រភព ឬជាគោលដៅនៃការធ្វើចរាចរទំនិញ និងការរៀបចំយុទ្ធសាស្ត្រក្នុងការអភិវឌ្ឍប្រទេស និងតំបន់ដែលរស់នៅ។

ដើម្បីសម្រេចបាននូវគោលដៅនេះ ការអភិវឌ្ឍកម្មវិធីសិក្សាថ្មីចំណេះទូទៅមុខវិជ្ជាភូមិវិទ្យា ត្រូវបានអភិវឌ្ឍដោយផ្អែកលើគោលនយោបាយអភិវឌ្ឍកម្មវិធីសិក្សាឆ្នាំ២០០៥ដល់ឆ្នាំ២០០៩ និងក្របខណ្ឌកម្មវិធីសិក្សាអប់រំចំណេះទូទៅនិងអប់រំបច្ចេកទេស ឆ្នាំ២០១៦ និងកម្មវិធីសិក្សារបស់ប្រទេសសិង្ហបុរីជាដើម។

## ២- គោលបំណង

មុខវិជ្ជាភូមិវិទ្យានៅកម្រិតមធ្យមសិក្សាទុតិយភូមិ មានគោលបំណងបណ្តុះបណ្តាលមូលដ្ឋានគ្រឹះដល់សិស្សានុសិស្សឱ្យទទួលបាននូវវិជ្ជាសម្បទា បំណិនសម្បទា និងចរិយាសម្បទា ដើម្បីក្លាយជាពលរដ្ឋពេញលេញ និងមានសមត្ថភាពជួយអភិវឌ្ឍសង្គមនិងប្រទេសជាតិ ប្រកបដោយសន្តិភាពសាមគ្គីភាពជាតិរឹងមាំ ដោយឈរលើទស្សនៈទូលំទូលាយមានចក្ខុវិស័យ របៀបគិត ការបង្កើតថ្មី និងរបកគំហើញបែបលក្ខណៈវិទ្យាសាស្ត្រ។

កម្មវិធីសិក្សាមធ្យមសិក្សាទុតិយភូមិនេះទាមទារឱ្យអ្នកសិក្សាសម្រេចបានលទ្ធផលសិក្សាដូចខាងក្រោម៖

### វិជ្ជាសម្បទា

- រៀបរាប់បានពីលក្ខខណ្ឌធម្មជាតិ លក្ខខណ្ឌសង្គម និងលក្ខខណ្ឌសេដ្ឋកិច្ចនៃប្រទេសកម្ពុជា និងបណ្តាប្រទេសមួយចំនួននៅក្នុងតំបន់ និងក្នុងពិភពលោក
- ពណ៌នាបានពីលក្ខណៈទូទៅនៃកសិកម្មពិភពលោក ពីកត្តាតំណាំងទីឧស្សាហកម្ម និងពីសញ្ញាណទូទៅនៃទេសចរណ៍
- រៀបរាប់បានពីកំណើនប្រជាជន និងបញ្ហាដែលកើតមាននៅប្រទេសអភិវឌ្ឍ និងប្រទេសកំពុងអភិវឌ្ឍន៍
- ពណ៌នាបានពីទំនាក់ទំនងជាសកលនៃទំនិញ ព័ត៌មាន និងមូលធន
- រៀបរាប់បានពីបញ្ហានគរូបនីយកម្ម បញ្ហាកង្វក់ បញ្ហាបាត់បង់ធនធានធម្មជាតិ និងគ្រោះមហន្តរាយធម្មជាតិនៅលើពិភពលោក និងនៅកម្ពុជា។

### បំណិនសម្បទា

- ប្រៀបធៀបពីលក្ខខណ្ឌធម្មជាតិ លក្ខខណ្ឌសង្គម លក្ខខណ្ឌសេដ្ឋកិច្ច បញ្ហាប្រជាជន នគរូបនីយកម្ម និងបញ្ហាធម្មជាតិរវាងប្រទេសកម្ពុជា ជាមួយប្រទេសក្នុងតំបន់ និងប្រទេសអភិវឌ្ឍលើពិភពលោក
- កំណត់បាននូវសកម្មភាព របៀបចាត់ចែង ដែនមានភាពជឿនលឿនសម្រាប់ជាមេរៀនពិសោធ ដើម្បីប្រើប្រាស់ក្នុងជីវភាពរស់នៅប្រចាំថ្ងៃតាមតំបន់ជាក់ស្តែង
- បង្ហាញឱ្យឃើញពីភាពចាំបាច់នៃបច្ចេកវិទ្យា ដែលមនុស្សអាចជម្នះបាននូវរបាំងធម្មជាតិនិងពង្វាតទីលំហ។

### ចរិយាសម្បទា

- បណ្តុះគំនិតអភិវឌ្ឍសង្គមជាតិ តាមរយៈគម្រូពិសោធជឿនលឿនពីប្រទេសក្នុងតំបន់ និងប្រទេសអភិវឌ្ឍនានាលើការរៀបចំ ដោះស្រាយបញ្ហា និងកិច្ចការពារបរិស្ថាន
- បណ្តុះភាពទទួលខុសត្រូវ មានគំនិតច្នៃប្រឌិតបង្កើតថ្មីក្នុងស្មារតីសហការ សាមគ្គីជាតិ និងអន្តរជាតិល្អប្រសើរ
- មានមោទនភាព និស្សុទិដ្ឋិនិយមខ្ពស់ ចំពោះធនធានធម្មជាតិដែលមានក្នុងមាតុប្រទេសរបស់ខ្លួន
- ជំរុញឆន្ទៈក្នុងការបង្កើនសក្តានុពលធនធានធម្មជាតិប្រទេសកម្ពុជាឱ្យក្លាយជាផលប្រយោជន៍ដល់ការអភិវឌ្ឍសេដ្ឋកិច្ចជាតិ និងលើកកម្ពស់ជីវភាពប្រជាជនឱ្យមានភាពជឿនលឿន។

## ៣- គោលគំនិតសំខាន់ៗ

១- កសិករ និងកសិកម្មពិភពលោក
២- ទីតាំង ឧស្សាហកម្ម និង លំហភូមិសាស្ត្រ
៣- ទេសចរណ៍
៤- ប្រទេស ឧស្សាហកម្មថ្មីនៅ អាស៊ីប៉ា ស៊ីហ្វិក
៥- កំណើន ប្រជាជន និងផលវិបាក
៦- នគរូបនីយកម្ម និង បញ្ហា
៧- មនុស្ស រៀបចំដែនដី
៨- មនុស្សបំផ្លាញធនធានធម្មជាតិ
៩- សកម្មភាពសមុទ្រ
១០- កង្វក់ និងការត្រួតពិនិត្យ
១១- ភាពចំណុះគ្នានៃសេដ្ឋកិច្ច
១២- លក្ខខណ្ឌធម្មជាតិកម្ពុជា
១៣- លក្ខខណ្ឌសង្គមកម្ពុជា
១៤- អភិវឌ្ឍន៍ប្រជាជនមិនស្មើគ្នានៅប្រទេសកម្ពុជា
១៥- សេដ្ឋកិច្ចកម្ពុជា
១៦- នគរូបនីយកម្មនៅកម្ពុជា
១៧- ប្រទេសមហា អំណាច
១៨- សហគមន៍អឺរ៉ុប ( EU)

## ៤- របាយម៉ោងសិក្សា

របាយម៉ោងមុខវិជ្ជាភូមិវិទ្យា នៅកម្រិតមធ្យមសិក្សាទុតិយភូមិ ត្រូវបានកំណត់ឱ្យបង្រៀន ៣៥ សប្ដាហ៍ ក្នុងមួយឆ្នាំសិក្សា  តាមបំណែងចែកម៉ោង ដូចក្នុងតារាងខាងក្រោម៖

| ល.រ | ថ្នាក់ទី | របាយម៉ោងក្នុងបណ្ដុំមុខវិជ្ជា | |
|---|---|---|---|
| | | បណ្ដុំវិទ្យាសាស្ត្រសង្គម | បណ្ដុំវិទ្យាសាស្ត្រ |
| ១ | ១០ | ១សប្ដាហ៍ = សិក្សា៣ម៉ោង<br>៣ម៉ x ៣៥សប្ដាហ៍ =១០៥ម៉/១ឆ្នាំសិក្សា | ១សប្ដាហ៍ = សិក្សា២ម៉ោង<br>២ម៉ x ៣៥សប្ដាហ៍ = ៧០ម៉/១ឆ្នាំសិក្សា |
| ២ | ១១ | ១សប្ដាហ៍ = សិក្សា៣ម៉ោង<br>៣ម៉ x ៣៥សប្ដាហ៍ =១០៥ម៉/១ឆ្នាំសិក្សា | ១សប្ដាហ៍ = សិក្សា២ម៉ោង<br>២ម៉ x ៣៥សប្ដាហ៍ = ៧០ម៉/១ឆ្នាំសិក្សា |
| ៣ | ១២ | ១សប្ដាហ៍ = សិក្សា៣ម៉ោង<br>៣ម៉ x ៣៥សប្ដាហ៍ = ១០៥ម៉/១ឆ្នាំសិក្សា | ១សប្ដាហ៍ = សិក្សា២ម៉ោង<br>២ម៉ x ៣៥សប្ដាហ៍ = ៧០ម៉/១ឆ្នាំសិក្សា |

**សម្គាល់:** បង្រៀន ២ ឬ ៣ ម៉ោងសិក្សាក្នុងមួយសប្ដាហ៍ និង ១ ម៉ោងសិក្សាមានរយៈពេល ៥០នាទី។

## ៥- ការណែនាំអនុវត្ត

សិស្សសង្ខេបខ្លឹមសារសំខាន់ៗ បន្ទាប់មកឱ្យសិស្សធ្វើការស្រាវជ្រាវឯកសារផ្សេងៗទៀតតាមរយៈកិច្ចការផ្ទះ ស្រង់បម្រែបម្រួលទិន្នន័យ ធ្វើជាតារាង ក្រាភិច ដ្យាក្រាម ធ្វើការប្រៀបធៀប និងការស្វែងរកគំនិតបង្កើតថ្មី ដោយៈ

- សិស្សដោះស្រាយបញ្ហា ជាបុគ្គល ជាដៃគូ ជាក្រុមតូច និងក្រុមធំ
- សិស្សឡើងចង្អុលបង្ហាញ រូបភាព ផែនទី
- សិស្សសរសេរបំពេញខ្លឹមសារ បំពេញឈ្មោះ បិទឈ្មោះលើរូបភាព លើផែនទី(ប្រឡងប្រណាំងជាបុគ្គល ជាក្រុមយេនឌ័រ)
- សិស្សដោះស្រាយបញ្ហា ជាបុគ្គល ជាដៃគូ ជាក្រុមតូច និងក្រុមធំ
- សិស្សប្តូរកិច្ចការអនុវត្ត ជួយកែលម្អ និងបំពេញបន្ថែម
- ការអនុវត្តល្បែងសិក្សា

រាល់ការបង្រៀនសកម្មភាពត្រូវប្រមូលផ្តុំនៅលើសិស្ស ចំណែកគ្រូគ្រាន់តែជាអ្នកដឹកនាំសម្របសម្រួល ដើម្បីធ្វើឱ្យសិស្សទទួលបាននូវវិជ្ជាសម្បទា បំណិនសម្បទា និងចរិយាសម្បទាឈានទៅសម្រេចតាមវត្ថុបំណងរបស់មេរៀននីមួយៗ។

## ៦- ការវាយតម្លៃ

កិច្ចការវាយតម្លៃគឺជាចំណុចសំខាន់ណាស់ ពីព្រោះវាគឺជាកិច្ចការសម្រាប់ការវាស់ស្ទង់អំពីអ្វីដែលសិស្សបានរៀន និងអ្វីដែលត្រូវជួយសិស្សក្នុងការរៀនសូត្រផងដែរ។ ជាញឹកញាប់ ការវាយតម្លៃនេះត្រូវធ្វើឡើងនៅចុងបញ្ចប់នៃមេរៀន ក្រោមប្រធានបទជាក់លាក់ណាមួយរបស់មេរៀននីមួយៗ និងវាយតម្លៃដំណាច់ឆមាស និងចុងឆ្នាំសិក្សា។ ការវាយតម្លៃអំពីអ្វីដែលសិស្សបានរៀន គឺជាកិច្ចការមួយដែលត្រូវធ្វើឡើងជាប្រចាំ និងជាផ្នែកមួយនៃការបង្រៀននិងរៀន ទាំងក្នុងនិងក្រៅថ្នាក់។ ការវាយតម្លៃគឺសំដៅរកព័ត៌មាន ឬភស្តុតាង ដើម្បីសន្និដ្ឋាន សម្រេចចិត្ត រកវិធី និងផ្តល់ធាតុចូលជួយដល់ការកែលម្អដំណើរការរៀនរបស់សិស្ស និងដំណើរការបង្រៀនរបស់គ្រូ ឱ្យឆ្លើយតបទៅនឹងស្តង់ដានៃលទ្ធផលសិក្សាដែលរំពឹងទុកក្នុងកម្មវិធីសិក្សាជាតិ។

**របៀបវាយតម្លៃលទ្ធផលសិក្សារបស់សិស្ស**

- **ការវាយតម្លៃលទ្ធផលសិក្សារបស់សិស្សត្រូវបានចែកជាបីផ្នែកៈ**
  - ការវាយតម្លៃលទ្ធផលសិក្សារបស់សិស្សតាមថ្នាក់
  - ការវាយតម្លៃលទ្ធផលសិក្សារបស់សិស្សធៀបនឹងកម្មវិធីសិក្សា
  - ការវាយតម្លៃតាមរយៈការប្រឡងថ្នាក់ជាតិ
- **ការវាយតម្លៃរួមមានៈ**
  - សំណួរផ្ទាល់មាត់
  - ការប្រតិបត្តិ ឬការសម្តែង
  - កិច្ចការផ្ទះ
  - កិច្ចការស្រាវជ្រាវ
  - គូររូប គូរផែនទី គូរដ្យាក្រាម ក្រាហ្វិក
  - សង្ខេបមេរៀន
  - បកស្រាយពន្យល់ ផែនទី រូបភាព រូបថត។

សម្គាល់៖ការវាយតម្លៃលទ្ធផលសិក្សារបស់សិស្សតាមថ្នាក់ ត្រូវធ្វើឡើងដោយគ្រូបង្រៀនតាមថ្នាក់ និងមុខវិជ្ជានីមួយៗក្នុង គោលបំណងវាយតម្លៃលទ្ធផលសិក្សារបស់សិស្សម្នាក់ៗ ដោយផ្តោតលើ វិជ្ជាសម្បទា បំណិនសម្បទា និងចរិយាសម្បទា ទៅតាម មេរៀននីមួយៗ។ ការវាយតម្លៃអាចធ្វើឡើងនៅពេលបង្រៀនតាមម៉ោង ពេលចប់មេរៀននីមួយៗ ឬវាយតម្លៃបញ្ចប់ជំពូកមេរៀន។

វិធីសាស្ត្រនៃការវាយតម្លៃមានដូចជា ការសួរសំណួរ ការធ្វើលំហាត់ ការពិភាក្សា ការសង្កេត ការធ្វើកិច្ចការផ្ទះ ការប្រឡង និងគម្រោងស្រាវជ្រាវ។ល។ ដើម្បីវាយតម្លៃលទ្ធផលសិក្សាក្នុងថ្នាក់រៀននីមួយៗ គ្រូបង្រៀនត្រូវប្រមូលកិច្ចការទាំងអស់យកមកធ្វើការវិភាគ សំយោគ និងបកស្រាយលទ្ធផលនៃការវាយតម្លៃដើម្បីសម្រេចជ្រើសរើស និងកែសម្រួលវិធីសាស្ត្របង្រៀន និងរៀន។

## ៧- តារាងកម្មវិធីសិក្សា

### ៧.១- កម្មវិធីសិក្សាលម្អិតថ្នាក់ទី១០

**ថ្នាក់វិទ្យាសាស្ត្រសង្គម ១០៥ម៉ោង (១ឆ្នាំ/៣៥សប្តាហ៍) (១សប្តាហ៍/៣ម៉)**

**ថ្នាក់វិទ្យាសាស្ត្រ ៧០ម៉ោង (១ឆ្នាំ/៣៥សប្តាហ៍) (១សប្តាហ៍/២ម៉)**

| ខ្លឹមសារ | លទ្ធផលរំពឹងទុក | ម៉ោង | |
|---|---|---|---|
| | | វិ.សង្គម | វិ.សាស្ត្រ |
| ជំពូក១ ៖ កសិករ និងកសិកម្មពិភពលោក | | (១៨ម៉) | (១២ម៉) |
| **មេរៀនទី១: លក្ខណៈទូទៅនៃកសិកម្ម**<br>១- ប្រភេទកសិកម្ម<br>ក- កសិកម្មប្រពៃណី<br>ខ- កសិកម្មទំនើប<br>២- ការងារចាំបាច់នៃកសិកម្ម<br>ក- ការរុករកដីថ្មី<br>ខ- បដិវត្តន៍កសិកម្ម | **វិជ្ជាសម្បទា**<br>- រៀបរាប់ពីកសិករ និងកសិកម្មពិភពលោក។<br>**បំណិនសម្បទា**<br>- ប្រៀបធៀបរវាងកសិកម្មប្រពៃណី និងកសិកម្មទំនើប<br>- បង្ហាញពីលក្ខណៈទូទៅនៃកសិកម្មប្រពៃណី កសិកម្មទំនើបនិងការងារចាំបាច់នៃកសិកម្ម<br>**ចរិយាសម្បទា**<br>- មានគំនិតច្នៃប្រឌិតក្នុងការរុករកដីថ្មីដើម្បីបំពេញឱ្យភាពចាំបាច់នៃកសិកម្ម។ | ៦ម៉ | ៤ម៉ |
| **រៀនទី២ : កសិកម្មតំបន់ត្រូពិក**<br>១- អាកាសធាតុអនុគ្រោះតែដីងាយខ្សោះជីជាតិ<br>២- តំបន់ត្រូពិចខ្លះមានការរីកចម្រើនខ្លាំង<br>៣- ដំណាំចម្ការធំៗបែបពាណិជ្ជកម្ម<br>៤- កសិកម្មចិញ្ចឹមពោះ<br>៥- កសិកម្មអតិផលនៅតាមជ្រលង | **វិជ្ជាសម្បទា**<br>- រៀបរាប់ពីអាកាសធាតុអនុគ្រោះនៅតំបន់ត្រូពិច។<br>**បំណិនសម្បទា**<br>- វិភាគពីទំនាក់ទំនងរវាងលក្ខខណ្ឌអាកាសធាតុ និងការធ្វើកសិកម្ម<br>- បច្ចេកទេសក្នុងការធ្វើកសិកម្មតាមបែបទំនើប<br>- បង្ហាញពីដំណាំចម្ការធំៗបែបពាណិជ្ជកម្ម | ៦ម៉ | ៤ម៉ |

| | | | |
|---|---|---|---|
| ក្នុងទ្វីបអាស៊ី | កសិកម្មចិញ្ចឹមពោះ និងកសិកម្មអតិផលនៅតាមជ្រលងក្នុងទ្វីបអាស៊ី។<br>**ចរិយាសម្បទា**<br>- មានគំនិតអភិវឌ្ឍវិស័យកសិកម្មឱ្យរីកចម្រើន | | |
| **មេរៀនទី៣ ៈ កសិកម្មប្រទេសឧស្សាហកម្មលូតលាស់**<br>១- កសិកម្មថ្មីនៅអឺរ៉ុប<br>២- កសិករអឺរ៉ុបខាងលិច<br>៣- កសិករសហរដ្ឋអាមេរិក<br>៤- កសិកម្មតាមបែបមូលធន<br>ក- ពាណិជ្ជកម្ម<br>ខ- កសិពាណិជ្ជកម្ម | **វិជ្ជាសម្បទា**<br>- រៀបរាប់ពីកសិករអឺរ៉ុបខាងលិចកសិករសហរដ្ឋអាមេរិក និងកសិកម្មតាមបែបមូលធន។<br>**បំណិនសម្បទា**<br>- ប្រៀបធៀបកសិកម្ម និងឧស្សាហកម្មសហរដ្ឋអាមេរិកជាមួយប្រទេសខ្លួន<br>- បង្ហាញពីការរៀបចំកសិកម្មថ្មីនៅអឺរ៉ុប។<br>**ចរិយាសម្បទា**<br>- ជ្រើសរើសយកគម្រូបច្ចេកទេសកសិកម្ម និងឧស្សាហកម្មតាមបែបទំនើបក្នុងការអភិវឌ្ឍប្រទេស។ | ៦ម៉ | ៤ម៉ |
| **ជំពូក២ ៖ ទីតាំង ឧស្សាហកម្ម និង លំហភូមិសាស្ត្រ** | | (១២ម៉) | (៩ម៉) |
| **មេរៀនទី១ : ឧស្សាហកម្មជាគន្លឹះនៃសេដ្ឋកិច្ច**<br>១- ឧស្សាហកម្ម<br>២- ប្រភេទឧស្សាហកម្ម<br>៣- ទម្ងន់ឧស្សាហកម្មនៅក្នុងសេដ្ឋកិច្ច | **វិជ្ជាសម្បទា**<br>- រៀបរាប់ពីប្រភេទនៃឧស្សាហកម្ម និងសារៈសំខាន់ឧស្សាហកម្មក្នុងសេដ្ឋកិច្ច។<br>**បំណិនសម្បទា**<br>- ធ្វើចំណែកថ្នាក់ប្រភេទឧស្សាហកម្ម<br>- បង្ហាញពីការរៀបចំនិងប្រភេទនៃឧស្សាហកម្ម និងសារៈសំខាន់ឧស្សាហកម្មក្នុងសេដ្ឋកិច្ច។<br>**ចរិយាសម្បទា**<br>- ទទួលយកនូវរាល់បច្ចេកទេសឧស្សាហកម្មរបស់ប្រទេសរីកចម្រើនដើម្បីលើកស្ទួយសេដ្ឋកិច្ចប្រទេស។ | ៤ម៉ | ៣ម៉ |
| **មេរៀនទី២ : បណ្តុំឧស្សាហកម្ម**<br>១- សកម្មភភាពឧស្សាហកម្មមុនស.វទី១៨<br>២- បណ្តុំលំហឧស្សាហកម្មនៅស.វទី១៩<br>៣- លំហឧស្សាហកម្មបច្ចុប្បន្ន | **វិជ្ជាសម្បទា**<br>- រៀបរាប់ពីសកម្មភាពឧស្សាហកម្មមុនសតវត្សន៍ទី១៨ និងបណ្តុំលំហឧស្សាហកម្មនៅស.វទី១៩ដល់បច្ចុប្បន្ន។<br>**បំណិនសម្បទា**<br>- ប្រៀបធៀបការវិវត្តនៃសកម្មភាព | ៤ម៉ | ៣ម៉ |

| | | | |
|---|---|---|---|
| | ឧស្សាហកម្មតាម សម័យកាលនិមួយៗ រហូតដល់បច្ចុប្បន្ន។<br>**ចរិយាសម្បទា**<br>- យកចិត្តទុកដាក់លើការសិក្សាស្រាវជ្រាវពីភាពរីកចម្រើននៃវិស័យឧស្សាហកម្មនៅលើពិភពលោក។ | | |
| **មេរៀនទី៣ : កក្តាតំណាំងទីនិងផលប៉ះពាល់បរិស្ថាន**<br>១- កក្តាតំណាំងទីឧស្សាហកម្ម<br>២- ផលប៉ះពាល់នៃឧស្សាហកម្ម ទៅលើបរិស្ថាន | **វិជ្ជាសម្បទា**<br>- រៀបរាប់ពីកក្តាតំណាំងទីឧស្សាហកម្ម និងផលប៉ះពាល់។<br>**បំណិនសម្បទា**<br>- កំណត់បានពីកក្តាតំណាំងទីឧស្សាហកម្ម និងផលប៉ះពាល់នៃឧស្សាហកម្ម ទៅលើបរិស្ថាន។<br>**ចរិយាសម្បទា**<br>- រៀបចំផែនការយុទ្ធសាស្ត្រក្នុងការកំណត់ទីតាំង ឧស្សាហកម្មសមស្របដើម្បីកាត់បន្ថយផលប៉ះពាល់បរិស្ថាន។ | ៤ម៉ | ៣ម៉ |
| ជំពូក៣ ៖ ទេសចរណ៍ | | (១២ម៉) | (៧ម៉) |
| **មេរៀនទី១ : សញ្ញាណទូទៅនៃទេសចរណ៍**<br>១- ដំណើរកម្សាន្ត និងទេសចរណ៍<br>២- ទេសចរណ៍ជាតិ និងអន្តរជាតិ | **វិជ្ជាសម្បទា**<br>- រៀបរាប់ពីសញ្ញាណទូទៅនៃទេសចរណ៍ តំបន់ទេសចរណ៍។<br>**បំណិនសម្បទា**<br>- បែងចែកប្រភេទទេសចរណ៍ឧទាហរណ៍ ទេសចរណ៍ធម្មជាតិ ទេសចរណ៍វប្បធម៌ ប្រវត្តិសាស្ត្រ<br>- បង្ហាញពីដំណើរកម្សាន្ត ទេសចរណ៍ ទេសចរណ៍ជាតិ និងអន្តរជាតិ។<br>**ចរិយាសម្បទា**<br>- អភិរក្ស និងអភិវឌ្ឍបន្ថែមតំបន់ទេសចរណ៍ក្នុងតំបន់។ | ៦ម៉ | ៤ម៉ |
| **មេរៀនទី២ : ធាតុផ្សំនៃទេសចរណ៍**<br>១- ការធ្វើដំណើរ<br>២- ការស្នាក់នៅ<br>៣- ការហូបចុក<br>៤- ការលំហែកម្សាន្ត | **វិជ្ជាសម្បទា**<br>- រៀបរាប់បានពីធាតុផ្សំនៃទេសចរណ៍ដូចជាការធ្វើដំណើរការស្នាក់នៅការហូបចុក និងការលំហែកម្សាន្ត។ | ៦ម៉ | ៣ម៉ |

| | | | |
|---|---|---|---|
| | **បំណិនសម្បទា**<br>- វិធីរៀបចំរមណីយដ្ឋានទេសចរណ៍<br>- បច្ចេកទេសប្រើប្រាស់ផ្សព្វផ្សាយគ្រប់រូបភាពដើម្បីបង្ហាញពីតំបន់ទេសចរណ៍។<br>**ចរិយាសម្បទា**<br>- បង្កើនសមត្ថភាពគ្រប់ជំនាញដើម្បីអភិវឌ្ឍវិស័យទេសចរណ៍ក្នុងតំបន់។ | | |
| ជំពូក៤ ៖ ប្រទេសឧស្សាហកម្មថ្មីនៅអាស៊ីប៉ាស៊ីហ្វិក | | (១២ម៉) | (៨ម៉) |
| **មេរៀនទី១ : ប្រទេសកូរ៉េខាងត្បូង**<br>១- លក្ខខណ្ឌធម្មជាតិ<br>២- លក្ខខណ្ឌសង្គម<br>៣- សេដ្ឋកិច្ច | **វិជ្ជាសម្បទា**<br>- រៀបរាប់ពីលក្ខខណ្ឌធម្មជាតិ លក្ខខណ្ឌសង្គម និងសេដ្ឋកិច្ច។<br>**បំណិនសម្បទា**<br>- ប្រៀបធៀបលក្ខខណ្ឌធម្មជាតិលក្ខខណ្ឌសង្គមនិងសេដ្ឋកិច្ចរបស់ប្រទេសកូរ៉េខាងត្បូងនិងសេដ្ឋកិច្ចរបស់ប្រទេស កូរ៉េខាងត្បូង<br>- បង្ហាញពីប្រទេសឧស្សាហកម្មថ្មីនៅអាស៊ីប៉ាស៊ីហ្វិក (ប្រទេសកូរ៉េខាងត្បូង)។<br>**ចរិយាសម្បទា**<br>- ទទួលយកនូវគម្រូដឹកនាំល្អៗផ្នែកសង្គម និងសេដ្ឋកិច្ចដើម្បីអភិវឌ្ឍប្រទេសរបស់ខ្លួន។ | ៣ម៉ | ២ម៉ |
| **មេរៀនទី២ : កោះតៃវ៉ាន់**<br>១- លក្ខខណ្ឌធម្មជាតិ<br>២- លក្ខខណ្ឌសង្គម<br>៣- សេដ្ឋកិច្ច | **វិជ្ជាសម្បទា**<br>- រៀបរាប់ពីលក្ខខណ្ឌធម្មជាតិលក្ខខណ្ឌសង្គម និងសេដ្ឋកិច្ចកោះតៃវ៉ាន់។<br>**បំណិនសម្បទា**<br>- ប្រៀបធៀបលក្ខខណ្ឌធម្មជាតិ លក្ខខណ្ឌសង្គមនិងសេដ្ឋកិច្ចរបស់កោះតៃវ៉ាន់ជាមួយប្រទេសកម្ពុជា<br>- បង្ហាញពីប្រទេសឧស្សាហកម្មថ្មីនៅអាស៊ីប៉ាស៊ីហ្វិក។<br>**ចរិយាសម្បទា**<br>- ទទួលយកនូវគម្រូដឹកនាំល្អៗផ្នែកសង្គម និងសេដ្ឋកិច្ចដើម្បីអភិវឌ្ឍប្រទេសរបស់ខ្លួន។ | ៣ម៉ | ២ម៉ |
| **មេរៀនទី៣ : ទឹកដីហុងកុង**<br>១- លក្ខខណ្ឌធម្មជាតិ<br>២- លក្ខខណ្ឌសង្គម | **វិជ្ជាសម្បទា**<br>- រៀបរាប់ពីលក្ខខណ្ឌធម្មជាតិ លក្ខខណ្ឌសង្គម និងសេដ្ឋកិច្ចប្រទេសកូរ៉េខាងត្បូង។ | ៣ម៉ | ២ម៉ |

| | | | |
|---|---|---|---|
| ៣- សេដ្ឋកិច្ច | **បំណិនសម្បទា**<br>- ប្រៀបធៀបលក្ខខណ្ឌលក្ខខណ្ឌធម្មជាតិ លក្ខខណ្ឌសង្គម និងសេដ្ឋកិច្ចរបស់ប្រទេសកូរ៉េខាងត្បូងជាមួយប្រទេសកម្ពុជា<br>- បង្ហាញពីប្រទេសឧស្សាហកម្មថ្មីនៅអាស៊ីប៉ាស៊ីហ្វិក។<br>**ចរិយាសម្បទា**<br>- ទទួលយកនូវគម្រូដឹកនាំល្អៗផ្នែកសង្គម និងសេដ្ឋកិច្ចដើម្បីអភិវឌ្ឍប្រទេសរបស់ខ្លួន។ | | |
| **មេរៀនទី៤ : ប្រទេសសិង្ហបុរី**<br>១- លក្ខខណ្ឌធម្មជាតិ<br>២- លក្ខខណ្ឌសង្គម<br>៣- សេដ្ឋកិច្ច | **វិជ្ជាសម្បទា**<br>- រៀបរាប់ពីលក្ខខណ្ឌធម្មជាតិ សង្គម និងសេដ្ឋកិច្ចនៅក្នុងប្រទេសសិង្ហបុរី ។<br>**បំណិនសម្បទា**<br>- ប្រៀបធៀបពីលក្ខខណ្ឌធម្មជាតិ សង្គមនិងសេដ្ឋកិច្ចនៅក្នុងប្រទេសសិង្ហបុរី ។<br>**ចរិយាសម្បទា**<br>- បណ្តុះស្មារតី និងយកគម្រូការអភិវឌ្ឍរបស់ប្រទេសសិង្ហបុរី។ | ៣ម៉ | ២ម៉ |
| **ជំពូក៥ ៖ កំណើនប្រជាជន និងផលវិបាក** | | (១៨ម៉) | (១២ម៉) |
| **មេរៀនទី១ : កំណើនប្រជាជនពិភពលោក**<br>១- ប្រវត្តិកំណើនប្រជាជន<br>ក- មុនឆ្នាំ១៧៥០<br>ខ- ពីឆ្នាំ១៧៥០ ដល់ឆ្នាំ១៩៥០<br>គ- ពីឆ្នាំ១៩៥០ ដល់បច្ចុប្បន្ន<br>២- បម្រែបម្រួលប្រជាជនពិភពលោក<br>ក- សម័យបុរាណ<br>ខ- សម័យអន្តរកាលប្រជាសាស្ត្រ<br>គ- សម័យទំនើប<br>៣- ភាពខុសគ្នានៃប្រជាសាស្ត្ររវាងលោកខាងជើងនិងលោកខាងត្បូង<br>៤- កំណើនប្រជាជននិងភាពក្រីក្រ | **វិជ្ជាសម្បទា**<br>- រៀបរាប់ពីកំណើនប្រវត្តិកំណើនអន្តរកាល និងផលវិបាកប្រជាជនលើពិភពលោក។<br>**បំណិនសម្បទា**<br>- វិភាគបានពីទំនាក់ទំនងរវាងកំណើនប្រជាជន និងភាពក្រីក្រ។<br>- បង្ហាញពីភាពខុសគ្នានៃប្រជាសាស្ត្ររវាងលោកខាងជើង និងលោកខាងត្បូង។<br>**ចរិយាសម្បទា**<br>- ចេះរៀបចំផែនការគ្រួសារ និងរិះរកវិធីក្នុងការបង្កើនប្រាក់ចំណូលដើម្បីលើកកម្ពស់ជីវភាពរស់នៅប្រចាំថ្ងៃ។ | ៦ម៉ | ៤ម៉ |

| | | | |
|---|---|---|---|
| **មេរៀនទី២ : ប្រជាជនពិភពលោកនៅដើមសហស្សវត្សទី៣**<br>១- ការប៉ាន់ស្មានចំនួនប្រជាជនតាមតំបន់ធំៗក្នុងពិភព លោក<br>២- ប្រទេសដែលមានប្រជាជនច្រើនជាងគេ<br>៣- ការវិវត្តប្រជាសាស្រ្ត<br>៤- ចំណោលប្រជាសាស្ត្រនៅឆ្នាំ ២០៥០ | **វិជ្ជាសម្បទា**<br>- រៀបរាប់បានពីការវិវត្តប្រជាសាស្ត្រនិងចំណោលប្រជាសាស្ត្រនៅឆ្នាំ ២០៥០។<br>**បំណិនសម្បទា**<br>- វិភាគពីការវិវត្តនៃចំនួនប្រជាជនលើពិភពលោក។<br>**ចរិយាសម្បទា**<br>- ប៉ាន់ស្មានចំនួនប្រជាជនតាមតំបន់ធំៗក្នុងពិភពលោក និងប្រទេសដែលមានប្រជាជនច្រើនជាងគេ។ | ៦ម៉ | ៤ម៉ |
| **មេរៀនទី៣ : របាយប្រជាជនពិភពលោក**<br>១- បណ្ដុំប្រជាជនសំខាន់ៗ<br>២- តំបន់ដែលមានដង់ស៊ីតេប្រជាជនខ្ពស់<br>៣- លំហដែលមានប្រជាជនមធ្យម | **វិជ្ជាសម្បទា**<br>- រៀបរាប់បានពីបណ្ដុំប្រជាជនសំខាន់ៗ តំបន់ដែល មានដង់ស៊ីតេប្រជាជនខ្ពស់ និងមធ្យម។<br>**បំណិនសម្បទា**<br>- កំណត់បានពីបណ្ដុំប្រជាជនសំខាន់ៗ តំបន់ដែលមានដង់ស៊ីតេប្រជាជនខ្ពស់ និងលំហដែលមានប្រជាជនមធ្យម។<br>**ចរិយាសម្បទា**<br>- គិតទុកជាមុននិងធ្វើចំណោលពីដង់ស៊ីតេប្រជាជន និងបញ្ហាដែលអាចកើតមាន។ | ៦ម៉ | ៤ម៉ |
| **ជំពូក៦ ៖ នគរូបនីយកម្ម និង បញ្ហា** | | **(២៤ម៉)** | **(១៧ម៉)** |
| **មេរៀនទី១ : ការរៀបចំទីក្រុង**<br>១- ទីក្រុងការកើនឡើងមុខងារនិងបញ្ហា<br>ក- ការកើនឡើងនៃទីក្រុង<br>ខ- មុខងារទីក្រុង<br>គ- បញ្ហាទីក្រុង<br>២- ការរៀបចំតំបន់ទីក្រុង<br>ក- ការរៀបចំតំបន់ទីក្រុងក្នុងប្រទេសកំពុងអភិវឌ្ឍ<br>ខ- ការរៀបចំតំបន់ទីក្រុងក្នុងប្រទេសអភិវឌ្ឍ | **វិជ្ជាសម្បទា**<br>- រៀបរាប់ពីការរៀបចំទីក្រុង ការកើនឡើងនៃចំនួនទីប្រជុំជន/ទីក្រុង មុខងារក្រុង និងបញ្ហាក្នុងទីក្រុង។<br>**បំណិនសម្បទា**<br>- កំណត់បានពីការរៀបចំតំបន់ទីក្រុងក្នុងប្រទេសកំពុង អភិវឌ្ឍ និងប្រទេសអភិវឌ្ឍ<br>- វិភាគបញ្ហាទីក្រុងក្នុងប្រទេសកម្ពុជា។<br>**ចរិយាសម្បទា**<br>- ស្វែងរកយុទ្ធសាស្ត្រដោះស្រាយបញ្ហាដែលកើតមានក្នុងទីក្រុង។ | ៦ម៉ | ៤ម៉ |
| **មេរៀនទី២:ការរៀបចំតំបន់ជនបទ**<br>១- តំបន់ជនបទ<br>ក- សញ្ញាណទូទៅតំបន់ជនបទ<br>ខ- ការរៀបចំផ្ទៃដីតំបន់ជនបទ | **វិជ្ជាសម្បទា**<br>- រៀបរាប់ពីសញ្ញាណទូទៅ ការរៀបចំផ្ទៃដី និងលំនៅស្ថានតំបន់ជនបទ។<br>**បំណិនសម្បទា**<br>- កំណត់បានពីការរៀបចំតំបន់ជនបទក្នុង | ៦ម៉ | ៤ម៉ |

| | | | |
|---|---|---|---|
| ២- លំនៅស្ថានតំបន់ជនបទ<br>៣- ការរៀបចំតំបន់ជនបទ<br>ក- ការរៀបចំតំបន់ជនបទក្នុងប្រទេសកំពុងអភិវឌ្ឍ<br>ខ- ការរៀបចំតំបន់ជនបទក្នុងប្រទេសអភិវឌ្ឍ | ប្រទេសកំពុងអភិវឌ្ឍ និងប្រទេសអភិវឌ្ឍ។<br>**ចរិយាសម្បទា**<br>- មានគំនិតបង្កើតថ្មីក្នុងការអភិវឌ្ឍតំបន់ជនបទកុំឱ្យមានគម្លាតខុសគ្នាខ្លាំងរវាង ទីក្រុង និងជនបទ។ | | |
| **មេរៀនទី៣ : បន្ទុះប្រជាជនក្រុងនៅប្រទេសអភិវឌ្ឍ**<br>១- បន្ទុះទីក្រុងខ្លាំងក្លាណាស់នៅប្រទេសកំពុងអភិវឌ្ឍ<br>២- ផលវិបាកដែលពិបាកជម្នះ | **វិជ្ជាសម្បទា**<br>- ពន្យល់ពីមូលហេតុនៃបន្ទុះទីក្រុងខ្លាំងក្លាណាស់នៅប្រទេសកំពុងអភិវឌ្ឍនិងផលវិបាក។<br>**បំណិនសម្បទា**<br>- វិភាគពីមូលហេតុដែលបណ្តាឱ្យមានបន្ទុះទីក្រុងខ្លាំងក្លាណាស់នៅប្រទេសកំពុងអភិវឌ្ឍ និងផលវិបាកដែល ពិបាកជម្នះ។<br>**ចរិយាសម្បទា**<br>- ស្វែងរកវិធានការទប់ស្កាត់ការធ្វើចំណាកជនបទរបស់ប្រជាជន។ | ៤ម៉ | ៣ម៉ |
| **មេរៀនទី៤ : ទីក្រុងក្នុងប្រទេសកំពុងអភិវឌ្ឍ**<br>១- ទីក្រុងដែលមានភាពផ្ទុយគ្នាខ្លាំង<br>២- ទីក្រុងដែលមានល្បឿនពីរ<br>៣- ទីក្រុងរីកធំហួសខ្នាត<br>៤- ចំណោលស្រុកស្រែនិងមូលហេតុ | **វិជ្ជាសម្បទា**<br>- រៀបរាប់ពីទីក្រុងដែលមានភាពផ្ទុយគ្នាខ្លាំង<br>**បំណិនសម្បទា**<br>- វិភាគបានពីទីក្រុងដែលមានល្បឿនពីរគឺទីក្រុងរីកធំហួសខ្នាត និងចំណោលស្រុកស្រែនិងមូលហេតុ។<br>**ចរិយាសម្បទា**<br>- ស្វែងរកវិធានការដើម្បីដោះស្រាយ និងទប់ស្កាត់ការរីកទំហំទីក្រុង និងធ្វើចំណាកជនបទរបស់ប្រជាជន។ | ៤ម៉ | ៣ម៉ |
| **មេរៀនទី៥ : ការប្រជែងខាងវិស័យនគរូនីយកម្ម**<br>១- ផលប្រយោជន៍នៃនគរូបនីយកម្ម<br>២- បញ្ហានគរូបនីយកម្ម<br>ក- កំណើនភាពក្រីក្រក្នុងក្រុង<br>ខ- ហេដ្ឋារចនាសម្ព័ន្ធ និងសេវាសាធារណៈមិនគ្រប់គ្រាន់<br>គ- បញ្ហាបរិស្ថាន<br>៣- ដំណោះស្រាយ | **វិជ្ជាសម្បទា**<br>- រៀបរាប់ពីផលប្រយោជន៍ បញ្ហានគរូបនីយកម្ម។<br>**បំណិនសម្បទា**<br>- បង្ហាញពីកំណើនភាពក្រីក្រ ហេដ្ឋារចនាសម្ព័ន្ធសេវាសាធារណៈមិនគ្រប់គ្រាន់បញ្ហាបរិស្ថាន និងដំណោះ ស្រាយក្នុងទីក្រុង។<br>**ចរិយាសម្បទា**<br>- ស្វែងរកវិធានការដើម្បីដោះស្រាយ និងទប់ស្កាត់ការរីកទំហំទីក្រុង ។ | ៤ម៉ | ៣ម៉ |

| ជំពូកទី៧ ៖ គ្រោះធម្មជាតិនៅប្រទេសកម្ពុជា | | (៩ម៉) | (៥ម៉) |
|---|---|---|---|
| **មេរៀនទី១ : ទឹកជំនន់និងខ្យល់ព្យុះ**<br>១- ទឹកជំនន់<br>ក- ទឹកជំនន់ជាអ្វី<br>ខ- ប្រភេទទឹកជំនន់<br>គ- បញ្ហាគ្រោះមហន្តរាយ<br>ឃ- ផលប៉ះពាល់នៃគ្រោះមហន្តរាយ<br>ង- ដំបូន្មានឱ្យរួចផុតពីគ្រោះទឹកជំនន់<br>២- ខ្យល់ព្យុះ<br>ក- ខ្យល់ព្យុះជាអ្វី ?<br>ខ- ផលប៉ះពាល់នៃខ្យល់ព្យុះ<br>គ- របៀបកាត់បន្ថយគ្រោះទឹកជំនន់ និងខ្យល់ព្យុះ និងផលប៉ាពាល់នៅពេលអនាគត | **វិជ្ជាសម្បទា**<br>- រៀបរាប់ពីគ្រោះទឹកជំនន់ ខ្យល់ព្យុះផលប៉ះពាល់ និងវិធីកាត់បន្ថយ គ្រោះទឹកជំនន់និងខ្យល់ព្យុះ និងផលប៉ាពាល់ នៅពេលអនាគត។<br>**បំណិនសម្បទា**<br>- កំណត់បានពីការត្រៀមបង្ការគ្រោះទឹកជំនន់ខ្យល់ព្យុះព្រមទាំងបង្ហាញឱ្យឃើញពីប្រភេទទឹកជំនន់ខ្យល់ព្យុះនិង ផលប៉ះពាល់ ។<br>**ចរិយាសម្បទា**<br>- ចូលរួមក្នុងការស្វែងរកវិធីកាត់បន្ថយគ្រោះទឹកជំនន់ និងខ្យល់ព្យុះនិងផលប៉ះពាល់នៅពេលអនាគត។ | ៥ម៉ | ៣ម៉ |
| **មេរៀនទី២ : គ្រោះរាំងស្ងួត**<br>១- គ្រោះរាំងស្ងួត<br>២- ប្រភេទ គ្រោះរាំងស្ងួត<br>៣- មូលហេតុនៃគ្រោះរាំងស្ងួត<br>៤- ផលប៉ះពាល់នៃគ្រោះរាំងស្ងួត<br>៥- វិធានការកាត់បន្ថយផលប៉ះពាល់គ្រោះរាំងស្ងួត | **វិជ្ជាសម្បទា**<br>- រៀបរាប់ពីគ្រោះរាំងស្ងួតនិងប្រភេទគ្រោះរាំងស្ងួតផលប៉ះពាល់និងវិធីកាត់បន្ថយគ្រោះរាំងស្ងួតនិងផលប៉ះពាល់នៅពេលអនាគត។<br>**បំណិនសម្បទា**<br>- កំណត់បានពីមូលហេតុដែលបណ្ដាលឱ្យមានគ្រោះរាំងស្ងួត និងផលប៉ះពាល់។<br>**ចរិយាសម្បទា**<br>- ចូលរួមក្នុងការស្វែងរកវិធីកាត់បន្ថយគ្រោះរាំងស្ងួតនិងផលប៉ះពាល់នៅពេលអនាគត។ | ៤ម៉ | ២ម៉ |

**សម្គាល់ ៖**

- ផ្នែកវិទ្យាសាស្ត្រសង្គមៈក្នុងមួយឆ្នាំសិក្សាបង្រៀន១០៥ម៉ោង។ ដូច្នេះគ្រូត្រូវបង្រៀនទៅតាមការបែងចែកម៉ោងសិក្សាដែលបានកំណត់នៅក្នុងមេរៀន នីមួយៗ។
- ផ្នែកវិទ្យាសាស្ត្រៈក្នុងមួយឆ្នាំសិក្សាបង្រៀន៧០ម៉ោង។ ដូច្នេះគ្រូត្រូវបង្រៀនទៅតាមការបែងចែកម៉ោងសិក្សា ដែលបានកំណត់នៅក្នុងមេរៀន នីមួយៗ។

## ៧.២- កម្មវិធីសិក្សាលម្អិតថ្នាក់ទី១១

**ថ្នាក់វិទ្យាសាស្ត្រសង្គម១០៥ម៉ោង (១ឆ្នាំ/៣៥សប្តាហ៍) (១សប្តាហ៍/៣ម៉)**

**ថ្នាក់វិទ្យាសាស្ត្រ ៧០ម៉ោង (១ឆ្នាំ/៣៥សប្តាហ៍) (១សប្តាហ៍/២ម៉)**

| ខ្លឹមសារ | លទ្ធផលរំពឹងទុក | ម៉ោង | |
|---|---|---|---|
| | | វិ.សង្គម | វិ.សាស្ត្រ |
| ជំពូក១ : មនុស្ស រៀបចំដែនដី | | (១៨ម៉) | ១២ម៉ |
| **មេរៀនទី១ : មនុស្សជម្នះរបាំរូប ហើយរៀបចំដែនដី**<br>១- របាំងភ្នំ<br>២- របាំងដីគោក<br>៣- របាំងទឹក<br>៤- ការពង្វាតយកលំហអាកាស | **វិជ្ជាសម្បទា**<br>- រៀបរាប់ពីការរៀបចំដែនដីនិងជម្នះរបាំងធម្មជាតិ (របាំងភ្នំរបាំងដីគោក របាំងទឹក) របស់មនុស្ស។<br>**បំណិនសម្បទា**<br>- បង្ហាញឱ្យឃើញពីភាពចាំបាច់នៃបច្ចេកវិទ្យាដែលមនុស្សអាចជម្នះបាននូវរបាំងធម្មជាតិ និងពង្វាតយកលំហអាកាស<br>- កំណត់បាននូវអ្វីដែលជារបាំងរូបនិងវិធីក្នុងការជម្នះនៅប្រទេសកម្ពុជា។<br>**ចរិយាសម្បទា**<br>- អភិវឌ្ឍន៍សង្គមតាមរយៈការដកស្រង់យកបទពិសោធល្អៗនិងសមស្របក្នុងការជម្នះរបាំងរូបទៅស្ថានភាពជាក់ស្តែងនៅកម្ពុជា។ | ៦ម៉ | ៤ម៉ |
| **មេរៀនទី២ : សកម្មភាពមនុស្ស និងកសិកម្ម**<br>១- ភូមិសាស្ត្រនៃដីដាំដុះ<br>២- តម្រូវការពង្រីកផ្ទៃដីដាំដុះ<br>៣- តម្រូវការបង្កើនទិន្នផល<br>៤- បដិវត្តន៍កសិកម្ម<br>ក- បដិវត្តន៍ស<br>ខ- បដិវត្តន៍បៃតង<br>គ- បដិវត្តន៍ក្រហម<br>៥- ផលិតផលមិនគ្រប់គ្រាន់ | **វិជ្ជាសម្បទា**<br>- រៀបរាប់ពីភូមិសាស្ត្រនៃដីដាំដុះ និង តម្រូវការពង្រីកផ្ទៃដីដាំដុះ តម្រូវការបង្កើនទិន្នផល<br>- ពណ៌នាបានពីបដិវត្តន៍កសិកម្ម (បដិវត្ត ស បៃតង និងក្រហម)។<br>**បំណិនសម្បទា**<br>- បង្ហាញពីផលិតផលមិនគ្រប់គ្រាន់សម្រាប់ផ្គត់ផ្គង់ប្រជាជននៅលើពិភពលោក<br>- វិភាគបានត្រឹមត្រូវពីមូលហេតុនៃការពង្រីកផ្ទៃដីដាំដុះនិងតម្រូវការបង្កើនទិន្នផលកសិកម្ម | ៦ម៉ | ៤ម៉ |

| | | | |
|---|---|---|---|
| | - ប្រៀបធៀបបានពីបដិវត្តកសិកម្មជាមួយនឹងកសិកម្មប្រទេសកម្ពុជា។<br>**ចរិយាសម្បទា**<br>- បណ្ដុះស្មារតីបង្កើតគំនិតថ្មីៗដើម្បីពង្រីកផ្ទៃដីដាំដុះនិងការបង្កើនទិន្នផល និងអភិវឌ្ឍវិស័យកសិកម្មដើម្បីលើស្ទួយសេដ្ឋកិច្ចជាតិ | | |
